សម្រាប់ការចុះផ្សាយបន្ទាន់៖ ថ្ងៃច័ន្ទ ទី ៦ មេសា ២០២០

លេខទំនាក់ទំនងសាលាក្រុង 781-286-8111

# សារលិខិតរបស់សាលាក្រុងជុំវិញ COVID-19៖ ថ្ងៃទី ៦ មេសា ២០២០

## *លោកអភិបាល Arrigo អនុវត្តវិធានការថ្មីៗ ដើម្បីកាត់បន្ថយល្បឿននៃការឆ្លង ហើយបន្តរឹតបន្តឹងវិធានការផ្សេងៗខណៈជំងឺកំពុងរាតត្បាត*

## *អ្នករស់នៅក្រុងទាំងអស់ ត្រូវពាក់ម៉ាស់រាល់ពេលដែលត្រូវចេញក្រៅផ្ទះ*

ថ្ងៃទី ៦ មេសា ២០២០- ក្រុមឆ្លើយតបរហ័សប្រចាំក្រុង Revere នៅតែបន្តការងារយ៉ាងសកម្ម ដើម្បីកាត់បន្ថយល្បឿននៃការឆ្លង និងការរាលដាលនៃជំងឺ COVID-19។ ហើយបានរៀបចំវិធានការរួចជាស្រេចដើម្បីទប់ទល់នឹងការឆ្លងនានា។ នៅថ្ងៃនេះ នាយកដ្ឋានសុខាភិបាលរបស់រដ្ឋ Massachusetts បានផ្ដល់ដំណឹងមកកាន់ក្រុមសុខាភិបាលប្រចាំក្រុង Revere ថា បានរកឃើញអ្នកឆ្លងមេរោគ COVID-19 ចំនួន ២៥៧ នាក់ នៅក្នុងក្រុង Revere។

នៅថ្ងៃនេះ លោកអភិបាល Arrigo បានបញ្ចេញវិធានការថ្មីជាច្រើន ដើម្បីការសហគមន៍ឲ្យចៀសផុតពីការរីករាលដាលនៃជំងឺ COVID-19 និងការពារអ្នករស់នៅទីក្រុង Revere ទាំងអស់។

- ការប្រកាសឲ្យអ្នកទៅលើឆ្នេរសមុទ្រមកផ្ទះវិញ តាមរថយន្តចល័តរបស់សាលាក្រុង៖ រថយន្តចល័តប្រចាំសាលាក្រុងត្រូវបានតម្លើងជាមួយបច្ចេកទេសសម្លេងជាភាសាអង់គ្លេស អេស្ពាញ អារ៉ាប់ និងព័រទុយហ្គាល់ ដើម្បីរំលឹកដល់អ្នកទាំងអស់គ្នាពីសារសំខាន់នៃការស្នាក់នៅផ្ទះ និងការថែទាំសុខភាពផ្ទាល់ខ្លួន និងសុខភាពគ្រួសារ។

- **រាល់ការសាងសង់ទាំងអស់ត្រូវផ្អាកដំណើរការ៖** រាល់ការដ្ឋានទាំងអស់ត្រូវផ្អាកការសាងសង់ រហូតដល់ថ្នាក់គ្រប់គ្រងនីមួយៗអាចចុះឈ្មោះជាភាគីទីបី ដែលបង់ប្រាក់ដោយអ្នកម៉ៅការ ដើម្បីផ្តល់ព័ត៌មានថ្មីៗដល់សាលាក្រុងពីរបៀបនៃការការពារសុវត្ថិភាពពី COVID-19។ សកម្មភាពនេះ បានត្រូវផ្តើមពីថ្ងៃទី ៣ មេសា នៅពេលដែលម្ចាស់គម្រោងសាងសង់បញ្ឈប់ការសាងសង់ រួមសណ្ឋាគារ ៣ របស់មជ្ឈមណ្ឌល Amazon។
- **ហាងទំនិញតូចៗ** (Convenience Stores) **ត្រូវបិទ៖** យោងតាមការរាយការណ៍ជាច្រើនបានឲ្យដឹងថា ហាងទំនិញមួយចំនួនកំពុងប្រមូលផ្តុំមនុស្សឲ្យលេងល្បែង Keno ដែលនេះជាការប្រឆាំងនឹងវិធានការការរក្សាគម្លាតក្នុងសង្គម និងការកំណត់ចំនួនមនុស្សក្នុងកន្លែងនីមួយៗ។ ដូច្នេះហាងទាំងនោះ នឹងត្រូវបិទ។

ក្រៅពីនោះ ក្នុងសប្តាហ៍នេះ សាលាក្រុងលើកទឹកចិត្តឲ្យរាល់អាជីវកម្មទាំងអស់ផ្តល់សេវាវេចខ្ចប់ drive thru និងការដឹកជញ្ជូន ដែលនាំឲ្យមនុស្សគ្មានការប៉ះពាល់គ្នា។

**សាលាក្រុងប្រកាសឲ្យអ្នករស់នៅទីក្រុងទាំងអស់ពាក់ម៉ាស់ រាល់ពេលដែលមានកាតព្វកិច្ចពេលចេញក្រៅផ្ទះ**

ក្រៅពីត្រូវរក្សាគម្លាតចម្ងាយ ៦ហ្វីតពីអ្នកដទៃ CDC បានណែនាំឲ្យអ្នកទាំងអស់គ្នាប្រើប្រាស់សម្លៀកបំពាក់ធម្មតាមកបិទបាំងមុខ ដើម្បីកាត់បន្ថយការរាលដាលនៃមេរោគ និងការពារការឆ្លងដោយមិនដឹងខ្លួន។ អ្នកអាចប្រើសម្លៀកបំពាក់ធម្មតាមកបិទបាំងបាន មិនចាំបាច់ប្រើប្រាស់ម៉ាស់ N-95 នោះទេ។ ប្រភេទម៉ាស់ទាំងនោះ គឺសម្រាប់អ្នកឯកទេសដែលធ្វើការនៅមន្ទីរព្យាបាល និងអ្នកឯកទេសផ្នែកពេទ្យប៉ុណ្ណោះ។

នាយកដ្ឋានថែទាំសុខភាពសាធារណៈរបស់រដ្ឋ Massachusetts បានចេញសេចក្តីណែនាំឲ្យប្រជាជនទាំងអស់ "ត្រូវស្នាក់នៅផ្ទះ"។ លោកអភិបាល Baker បានធ្វើការហាមមិនឲ្យមានការជួបជុំមនុស្ស លើសពី ១០ នាក់។ ការស្នាក់នៅផ្ទះ មានន័យថា ជៀសវាងការធ្វើការ ឬធ្វើសកម្មភាពណាដែមិនចាំបាច់ ក្នុងរយៈពេល ២ សប្តាហ៍ខាងមុខ។ ប្រជាជនដែលមានអាយុលើសពី ៧០ និងអ្នកមានសុខភាពទន់ខ្សោយ គួរតែកាត់បន្ថយការជួបជុំ ឬប៉ះពាល់ជាមួយមនុស្សទូទៅតាមដែលអាចធ្វើបាន។

តាមរយៈការណែនាំរបស់មជ្ឈមណ្ឌលគ្រប់គ្រងជំងឺ Centers for Disease Control បានប្រាប់ពីវិធីងាយៗមួយចំនួនដើម្បីការពារខ្លួនពីវីរ៉ុសក្លូរ៉ូណារួមមាន៖ លាងដៃឲ្យបានញឹកញាប់ ជៀសវាងការនៅជិតអ្នកដែលឈឺ ត្រូវស្នាក់នៅផ្ទះពេលឈឺ ខ្ទប់មាត់ពេលក្អក និងកណ្តាស់ សម្អាតដៃ និងរំងាប់មេរោគលើរបស់ដែលអ្នកប៉ះញឹកញាប់។

លោកអភិបាលក្រុង និងសមាជិកនៃក្រុមឆ្លើយតបរហ័សនៅតែបន្តមានកិច្ចប្រជុំរៀងរាល់ថ្ងៃ ដើម្បីសង្ខេបស្ថានការណ៍ថ្មីៗ។ មន្ត្រីនានាទីក្រុង និងក្រុមសហព័ន្ធក៏ចូលរួមក្នុងការសង្ខេបស្ថានការណ៍ប្រចាំថ្ងៃនេះ ដើម្បីសម្របសម្រួល និងរកមធ្យោបាយដោះស្រាយបញ្ហាផ្ទៃក្នុង។ ការអាប់ដេតទាំងអស់ នឹងត្រូវធ្វើជាទៀងទាត់នៅគេហទំព័រ Revere.org/coronavirus និងតាមបណ្តាញសង្គម។

## សេវាកម្មរបស់ក្រុង

- លោកអភិបាលក្រុង Arrigo បានប្រកាសពីភាពអាសន្ននៃការឆ្លងនៅក្នុងក្រុង Revere កាលពីថ្ងៃ ១៩ មិន ២០២០។
- សេវាកម្មមូលដ្ឋានរបស់ទីក្រុងដែលផ្តល់ដោយប៉ូលីស Revere អគ្គីភ័យ, EMS មន្ទីរសាធារណការ និង Revere 311 នឹងបន្តផ្តល់ជូនប្រជាពលរដ្ឋ ដោយគ្មានការរំខានណាមួយឡើយ។
- អ្នករស់នៅ Revere គួរតែ Subscribe សេវាបញ្ជូនព័ត៌មានតាមអ៊ីម៉ែល និងសារជាអក្សរតាម revere.org/coronavirus ដើម្បីទទួលបានព័ត៌មានថ្មីៗ។
- Revere 311 នៅតែមានបុគ្គលិក ចាំឆ្លើយសំណួរ ឬដោះស្រាយកង្វល់ផ្សេងៗជូនប្រជាបលរដ្ឋ។ សូមទាក់ទងមកកាន់ 311 ឬ 781-286-8311 ឬអ៊ីម៉ែលមក Revere311@revere.org ។
- អាគារសាធារណៈក្នុងទីក្រុងទាំងអស់ត្រូវបានបិទ រហូតដល់មានការជូនដំណឹងបន្ថែម។ សេវាកម្មនានានៅតែផ្តល់ប្រជាជនតាមគេហទំព័រ Revere.org។
- រាល់សួនច្បារ និងសួនកុមារទាំងអស់ត្រូវបានបិទ រហូតដល់ថ្ងៃជូនដំណឹងបន្ថែម។
- សាលារដ្ឋនៅក្នុងក្រុង Revere នឹងមានចែកអាហារខ្ចប់ សម្រាប់សិស្សទាំងអស់ និងគ្រួសារ។ អាហារពេលព្រឹក និងថ្ងៃត្រង់ នឹងចែកជូនដល់កុមារដែលត្រូវការពីចន្ទ ដល់សុក្រ ពីម៉ោង ១០ ដល់ ១១ ព្រឹក និង ម៉ោង ១១ ដល់១ ថ្ងៃត្រង់។
- អ្នកអាចស្វែងរកបណ្តាញផ្តល់ជំនួយទៅមកនៅលើ Revere.org ។ នៅទីនោះ អ្នកអាចរកបានជំនួយយ៉ាងទូលំទូលាយ ប្ញករួមទាំងផ្នែកចំណីអាហារ សេវាថែទាំងសុខភាព សេវាធ្វើដំណើរ សិទ្ធជ្រកកោន និងសេវាផ្សេងៗទៀត។ ព័ត៌មានទាក់ទងនឹងសេវាទាំងនេះ នឹងមានការអាប់ដេតជារៀងរាល់ថ្ងៃនៅម៉ោង ៤ ល្ងាច។
- ទីក្រុង Revere បានបង្កើត ទំព័រ មួយ ដែលបង្ហាញព័ត៌មានពីដំណោះស្រាយ និងជំនួយទៅដល់អ្នកដែលបានរងផលប៉ះពាល់ ដូចជាអាជីវកម្មខ្នាតតូច នយោជក អាជីវកម្មមិនយកប្រាក់ចំណេញ និងកម្មករ។ ទំព័រនេះនឹងមានការអាប់ដេតជាប្រចាំថ្ងៃ រាល់ពេលដែលអ្វីៗមានការប្រែប្រួល។
- ក្រុមស្ម័គ្រចិត្ត volunteer database នឹងបើករាល់ថ្ងៃសុក្រ សម្រាប់អ្នកដែលចង់រកកម្មី ឬជំនួយក្នុងរយៈពេលច្រើនសប្តាហ៍ខាងមុខ។ អ្នកដែលបានចុះឈ្មោះធ្វើជាអ្នកស្ម័គ្រចិត្តរួច នឹងមានក្រុមការងារទាក់ទងទៅឆាប់ៗក្រោយបំពេញឯកសារគ្រប់គ្រាន់។

###